ពង្រាងសង្ខេបសំរាប់
គោលនយោបាយ

CDRI គឺជាវិទ្យាស្ថានកម្ពុជាឯករាជ្យឈានមុខគេ
សំរាប់ការស្រាវជ្រាវពីគោលនយោបាយអភិវឌ្ឍន៍

ឆ្នាំ 2008 លេខ 02

# ផលប៉ះពាល់នៃម្ហូបអាហារមានថ្លៃខ្ពស់នៅកម្ពុជា

ដោយលោក ច័ន្ទ សុផល*

ដូចនៅប្រទេសជាច្រើនទៀតដែរ ថ្លៃទំនិញ និងសេវាផ្សេងៗនៅកម្ពុជា បានស្ទុះឡើងនៅឆ្នាំ២០០៨ ជាពិសេស ប្រេងឥន្ធនៈ និងម្ហូបអាហារ ដែលធ្វើឲ្យអត្រាអតិផរណាពីមួយឆ្នាំទៅមួយឆ្នាំ ក្នុងរយៈពេលពីខែមីនា–សីហា ឡើងដល់ជាង ២០% ។ ដោយឡែក ម្ហូបអាហារឡើងថ្លៃ ៣៦,៨% ហើយការដឹកជញ្ជូន និងសំភារៈក្នុងផ្ទះ ឡើងថ្លៃ ២៧% ស្មើគ្នា (ក្រាហ្វិក ១) ។ អតិផរណានេះបង្កដោយសារកំណើនតំរូវការក្នុងពិភពលោក និងកំណើនតំរូវការមួយចំនួនក្នុងស្រុក រីឯការផ្គត់ផ្គង់បានរួមចុះរីកើនតំលៃ ដោយសារកំណើនចំណាយលើប្រេងឥន្ធនៈ ។ ក្នុងស្ថានភាពនេះ សេដ្ឋកិច្ចកម្ពុជាបានទទួលទាំងផលប៉ះពាល់អវិជ្ជមានសំរាប់អ្នកប្រើប្រាស់ និងឱកាសល្អសំរាប់ឲ្យផលិតកររកចំណូលបានកាន់តែច្រើន ។

អតិផរណាកំរិតខ្ពស់ ប៉ះពាល់អ្នកក្រីក្រធ្ងន់ធ្ងរជាង ។ អង្ករគ្រប់ប្រភេទដែលជាអាហារមូលដ្ឋាននៅកម្ពុជា បានឡើងថ្លៃដល់ ១០០% ពីខែមីនា–កក្កដា ២០០៧ ដល់ មីនា–កក្កដា ២០០៨ ក្នុងនេះ សាច់ឡើង

## ក្រាហ្វិក ១: សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅភ្នំពេញ ពីខែកក្កដា ២០០៧ ដល់ កក្កដា ២០០៨




ប្រភព: វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ

* លោក ច័ន្ទ សុផល ប្រធានស្រាវជ្រាវជាន់ខ្ពស់ ផ្នែកសេដ្ឋកិច្ច ពាណិជ្ជកម្ម និងសហប្រតិបត្តិការក្នុងតំបន់ របស់វិទ្យាស្ថាន CDRI ។ ឯកសារនេះ ផ្អែកលើការសិក្សាស្តីពីផលប៉ះពាល់នៃការឡើងថ្លៃម្ហូបអាហារ ដែលឧបត្ថម្ភដោយកម្មវិធីស្បៀងអាហារពិភពលោក កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ ធនាគារពិភពលោក អុកស្វាមអាមេរិក វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា និងអង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ ។

## តារាង ១: ការកាន់កាប់ដី (%នៃគ្រួសារ)

| | អ្នកគ្មានដី | <0.5 ហ.ត | 0.5–1 ហ.ត | 1–3 ហ.ត | >3 ហ.ត | សរុប |
|---|---|---|---|---|---|---|
| តំបន់វាលទំនាប | 24.8 | 26.3 | 21.6 | 20.0 | 7.2 | 100.0 |
| តំបន់ទន្លេសាប | 19.2 | 17.3 | 20.5 | 29.7 | 13.3 | 100.0 |
| តំបន់ខ្ពង់រាប | 11.1 | 20.6 | 27.4 | 31.3 | 9.5 | 100.0 |
| តំបន់ឆ្នេរ | 22.8 | 34.1 | 22.0 | 17.9 | 3.3 | 100.0 |
| សរុប | 21.1 | 23.4 | 22.1 | 24.4 | 9.1 | 100.0 |

ប្រភព: អង្កេតថ្នាក់ជាតិ លើ ២២៣៥គ្រួសារ នៅខែមិថុនា ២០០៨ ធ្វើឡើងដោយ CDRI

ថ្លៃ ៥០–៧០% រីឯត្រីនិងបន្លែឡើងថ្លៃ ២០–៣០% ។ ការឡើងថ្លៃម្ហូបអាហារ បានប៉ះពាល់អវិជ្ជមានដល់ប្រជាជនគ្រប់ស្រទាប់ ហើយទំហំនៃការប៉ះពាល់ប្រែប្រួលទៅតាមស្ថានភាពសេដ្ឋកិច្ចនៃគ្រួសារនីមួយៗ ។ ប្រជាជនក្រីក្រជាងគេ ៤០% ត្រូវចំណាយ ៧០%នៃចំណូលរបស់ខ្លួនទៅលើម្ហូបអាហារ យោងតាមអង្កេតសេដ្ឋកិច្ច–សង្គមកិច្ចកម្ពុជាឆ្នាំ ២០០៤ ។ ដូច្នេះហើយ អ្នកក្រីក្រ និងអ្នកទិញសុទ្ធនូវម្ហូបអាហារទទួលរងគ្រោះធ្ងន់ធ្ងរជាងគេដោយសារការឡើងថ្លៃយ៉ាងខ្ពស់នេះ ។ ប្រជាជនទាំងនេះភាគច្រើនរស់នៅក្នុងតំបន់ក្រីក្រ ។ គ្រួសារមានអសន្តិសុខស្បៀង ភាគច្រើនរស់នៅតំបន់ទន្លេសាប និងតំបន់វាលទំនាប ។ អ្នកក្រីក្រនៅតាមទីប្រជុំជនក៏ត្រូវប៉ះពាល់យ៉ាងខ្លាំងដែរ ទោះបីពួកគេមានឱកាសរកចំណូលច្រើនជាងក្តី ។

ជាផលប៉ះពាល់ល្អ គេឃើញថា កសិផលជាច្រើនបានឡើងថ្លៃ និងផ្តល់ចំណេញដល់កសិករប្រហែល ៣០% ដែលមានផលដំណាំនៅសល់សំរាប់លក់ ។ ការសិក្សារបស់យើងបានរកឃើញថា កសិករអ្នកដាំស្រូវ ដំឡូងឈើ ពោត រឺសណ្តែកសៀងនៅឆ្នាំនេះ ដែលមានប្រហែល ២៥% នៃកសិករទាំងអស់ បានទទួលផលចំណេញសុទ្ធពីការឡើងថ្លៃផលិតផល ។ ប៉ុន្តែផលប៉ះពាល់ល្អនេះវាមានកំរិត ពីព្រោះប្រជាជនជនបទ មិនមែនមានកសិផលនៅសល់សំរាប់លក់គ្រប់គ្នានោះទេ គឺមានតែ ៣៤% ដែលមានដូច្នេះ រីឯ ២១% ទៀតជាគ្រួសារគ្មានដីធ្លី និង ៤៥% មានដីតិច (មិនលើសពី ១ហិកតា/គ្រួសារ) ។ តារាង១ បង្ហាញពីស្ថានភាព កាន់កាប់ដីតាមតំបន់ ។ អ្នកគ្មានដី និងអ្នកមានដីតិចត្រូវមានចំណូលជាប្រាក់ច្រើនជាង ដើម្បីទប់ទល់នឹងការឡើងថ្លៃម្ហូបអាហារ ។

ជាភព្វល្អ ថ្លៃឈ្នួលសំរាប់ពលកម្មពេលថ្ងៃដូចជា ការដកស្ទូង ច្រូតកាត់ ជំរះស្មៅ កាប់ឆ្ការព្រៃរិចរិល ដែលជាប្រភពចំណូលចំបងរបស់អ្នកគ្មានដី និងអ្នកមានដីតិច បានកើនប្រហែល ៥០% ក្នុងឆ្នាំកន្លងទៅ ។ ជាមធ្យម ប្រាក់ឈ្នួលប្រចាំថ្ងៃកើនពី ៧៥០០ ដល់ ១១.០០០រៀល (១,៨៣–២,៦៨ដុល្លារ) ពីឆមាសទី២ ឆ្នាំ២០០៧ ដល់ឆមាសទី១ ឆ្នាំ២០០៨ (តារាង ២) ។ កំណែតំរូវតាមទីផ្សារនេះ បានជួយប្រជាជនជាច្រើននាក់ឲ្យរក្សាស្ថានភាព នៅដដែលបាន រឺក៏មិនចុះក្រកាន់តែខ្លាំងទៀត ។ ទោះយ៉ាងនេះក្តី មានតែគ្រួសារប្រហែល ៣០% រឺប្រហែល ៥០% នៃអ្នកគ្មានដី/អ្នកមានដីតិច ដែលបានធ្វើពលកម្មពេលថ្ងៃមួយចំនួន ក្នុងខែមករា–មេសា ២០០៨ (តារាង ៣) ។ ថ្វីបើអ្នកគ្មានដី/អ្នកមានតិច មួយចំនួនបានធ្វើការងារផ្សេងទៀតក្រៅពី

## តារាង ២: ថ្លៃឈ្នួលមធ្យមនៃពលកម្មពេលថ្ងៃ

| | 2007 | 2008 | 2008 | បំរែបំរួលជា% |
|---|---|---|---|---|
| ប្រភេទពលកម្មពេលថ្ងៃ | រដូវវស្សា (កក្កដា–ធ្នូ) | រដូវប្រាំង (មករា–មេសា) | ឧសភា–កក្កដា | កក្កដា–ធ្នូ ២០០៧ ដល់ ឧសភា–កក្កដា ២០០៨ |
| | (រៀល/ថ្ងៃ/នាក់) | | | |
| ដកស្ទូង | 6000 | 9250 | 10,000 | 67 |
| ច្រូតកាត់ | 7500 | 9000 | 11,000 | 47 |
| ជំរះស្មៅ | 7500 | 9000 | 11,000 | 47 |
| ដាំដំណាំ | 8000 | 10,000 | 11,000 | 38 |
| កាប់ឆ្ការព្រៃគម្ពោត/ព្រៃរិចរិល | 9000 | 12,500 | 13,000 | 44 |
| ការងារសំណង់ | 10,000 | 11,000 | 13,500 | 35 |

ប្រភព: អង្កេតថ្នាក់ជាតិលើ ២២៣៥គ្រួសារ នៅខែមិថុនា ២០០៨ ធ្វើឡើងដោយ CDRI

## តារាង ៣: ភាគរយគ្រួសារលក់ពលកម្មពេលថ្ងៃ

| | កក្កដា–ធ្នូ ២០០៧ | មករា–មេសា ២០០៨ | ឧសភា–មិថុនា ២០០៨ |
|---|---:|---:|---:|
| តំបន់វាលទំនាប | 35 | 33 | 26 |
| តំបន់ទន្លេសាប | 51 | 31 | 25 |
| តំបន់ខ្ពង់រាប | 42 | 32 | 23 |
| តំបន់ឆ្នេរ | 34 | 13 | 14 |

*ប្រភព: អង្កេតថ្នាក់ជាតិ លើ ២២៣៥គ្រួសារ នៅខែមិថុនា ២០០៨ ធ្វើឡើងដោយ CDRI*

ពលកម្មពេលថ្ងៃក្តី ក៏ក្នុងចំណោម ពួកគេនេះមានយ៉ាងហោចណាស់ ២៥% ដែរ ដែលមិនអាចរកចំណូលបានច្រើនថែមទៀតដោយសារកង្វះការងារ ហើយក៏ត្រូវប៉ះពាល់ខ្លាំងជាងគេពីការឡើងថ្លៃម្ហូបអាហារ ។ អ្នកទាំងនេះច្រើនតែរស់នៅតាមតំបន់ក្រីក្រ ជាពិសេសតំបន់ទន្លេសាប និងវាលទំនាបមួយភាគ ដែលមានសក្ខានុពលតិចសំរាប់ការបង្កើតប្រាក់ចំណូល ។ សព្វថ្ងៃនេះ មានឱកាសរកចំណូលច្រើនណាស់នៅតាមតំបន់ខ្ពង់រាប ដោយសារកំណើនការបំប្លែងដីព្រៃរិចរិលទៅជាដីកសិកម្ម ។

អ្នកក្រីក្រខ្លាំងទាំងនៅទីក្រុងនិងជនបទ ត្រូវតស៊ូជារៀងរាល់ថ្ងៃដើម្បីបានម្ហូបអាហារគ្រប់គ្រាន់ ។ អ្នកទាំងនេះ តំណាងឲ្យ ២០% នៃប្រជាជនសរុប និងត្រូវ "រកមួយថ្ងៃហូបមួយថ្ងៃ" ដោយប្រើចំណូលប្រមាណ ២–៣ដុល្លារក្នុងមួយថ្ងៃ ដើម្បីទិញអង្ករ និងម្ហូបអាហារចាំបាច់ឯទៀតសំរាប់មួយថ្ងៃនោះ ។ ដោយប្រើនិយមន័យរបស់អង្គការស្បៀងអាហារពិភពលោក អង្កេតបានរកឃើញថា គ្រួសារ ១៩,១% ពុំមានអាហារហូបចុក "សមរម្យ" ទេ ក្នុងនេះ ៧% មានការហូបចុក "អន់ខ្សោយ" ១២,១% ហូបចុក "ស្ទើរខ្វះស្ទើរគ្រប់" ហើយក្រៅពីនេះមានអាហារហូបចុកសមរម្យ (ក្រាហ្វិក ២) ។ ម្យ៉ាងទៀត គ្រួសារ ៥០% រាយការណ៍ថា បានកាត់បន្ថយការហូបចុក ដើម្បីដោះស្រាយបញ្ហាម្ហូបអាហារឡើងថ្លៃ ។ មធ្យោបាយនេះបានគំរាមកំហែងដល់កំរិតអាហារូបត្ថម្ភ ធ្វើឲ្យសុខភាពចុះទន់ខ្សោយ ហើយអាចមានផលប៉ះពាល់អាក្រក់យូរ អង្វែង ។ បញ្ហាបោះបង់ការសិក្សាមានច្រើនបំផុតក្នុងចំណោមគ្រួសារ ជួបអសន្តិសុខស្បៀង ដោយ ១៣% នៃគ្រួសារទាំងនេះមានកូនបោះបង់ការសិក្សានៅខែមករា ២០០៨ និង ២២% មានកូនបោះបង់ការសិក្សា នៅខែមិថុនា ២០០៨ ។ តួលេខនេះបានបញ្ជាក់គាំទ្រដល់ការព្រួយបារម្ភពីផលប៉ះពាល់រយៈពេលវែងនៃ

## ក្រាហ្វិក ២: ទីតាំងគ្រួសារមានអសន្តិសុខស្បៀង



ថ្លៃដ៏ខ្ពស់នៃម្ហូបអាហារ ។

សហគមន៍នេសាទ ស្ថិតក្នុងចំណោមអ្នកត្រូវប៉ះពាល់ធ្ងន់ធ្ងរជាងគេ ។ ការឡើងថ្លៃអង្ករមួយជាពីរ បានរុញច្រានគ្រួសារនេសាទឲ្យចុះក្រីកាន់តែខ្លាំង ។ ប្រាក់ចំណូលប្រចាំថ្ងៃរបស់ពួកគេថយចុះយ៉ាងខ្លាំង ដោយសារការថយចុះបរិមាណត្រីចាប់បាន និងកំណើនចំណាយប្រចាំថ្ងៃ ។ ត្រីដែលពួកគេចាប់បាន អាចលក់បានថ្លៃជាងមុន ២០% ក៏ពិតមែន ប៉ុន្តែមិនអាចប៉ះប៉ូវការឡើងថ្លៃធាតុចូលផ្សេងៗ និងឧបករណ៍នេសាទបានទេ ។

នៅសល់ ៤–៥ខែទៀត ទើបដល់ពេលប្រមូលផលស្រូវនៅចុងឆ្នាំ២០០៨ ដូច្នេះគ្រួសារប្រហែល ៧៤% នឹងត្រូវអស់ស្តុកស្រូវអង្ករដែលខ្លួនមានសព្វថ្ងៃ ហើយត្រូវពឹងផ្អែកលើការទិញពីទីផ្សារ មុនពេលដល់ស្រូវថ្មី ។ ពីខែមិថុនា ដល់ ធ្នូ ភូមិគំរូតាងត្រូវការស្រូវសរុប ៣២៨.៨៩០តោន ដែលមានតំលៃប្រហែល ១១៥លានដុល្លារ ។ ប្រសិនបើស្រូវពុំមានលំហូរចេញសុទ្ធពីស្តុកដែលមានស្រាប់ ហើយប្រសិនបើស្តុកស្រូវមានស្រាប់នៅកម្ពុជា ត្រូវទុកសំរាប់តែការចែកចាយ និងប្រើប្រាស់ក្នុងស្រុក នៅក្នុងប្រទេសកម្ពុជានឹងពុំមានកង្វះសុទ្ធនៃស្រូវអង្ករទេ ។

អ្នកផលិតសុទ្ធនៃស្រូវអង្ករមួយចំនួន ដែលប្រហែលស្ថិតក្នុងចំណោមគ្រួសារជនបទ ៣៥% ជាអ្នកមានដីកសិកម្មច្រើនជាង ១ហ.ត គឺបានទទួល រឺប្រហែលនឹងបានទទួលផលចំនេញពីការឡើងថ្លៃស្រូវអង្ករយ៉ាងខ្ពស់ ។ ផ្អែកតាមតំលៃធាតុចូលកសិកម្ម និងថ្លៃទីផ្សារនៃស្រូវក្នុងពេលធ្វើអង្កេតនៅខែមិថុនា ២០០៨ ការផលិតស្រូវនៅឆ្នាំ២០០៨

## តារាង ៤: ផលប៉ះពាល់នៃកំនើនថ្លៃលើប្រាក់ចំនេញពីផលដំណាំ (ក្នុងមួយហិកតាក្នុងមួយរដូវ)

| ផលដំណាំ | រដូវប្រាំង | | | រដូវវស្សា | | |
|---|---|---|---|---|---|---|
| | **2007** | **2008** | បំរែបំរួល (%) | 2007 | 2008* | បំរែបំរួល (%) |
| អង្ករ | | | | | | |
| ទិន្នផល (តោន) | 3.7 | 3.7 | 0 | 1.9 | 1.9 | 0 |
| ថ្លៃទិញផ្ទាល់ពីកសិករ (ដុល្លារ/តោន) | 180 | 250 | 39 | 225 | 320 | 42 |
| ប្រាក់ចំនូលដុល (ដុល្លារ) | 663 | 921 | 39 | 427 | 608 | 42 |
| ចំនាយផលិតកម្មសរុប (ដុល្លារ) | 233 | 350 | 50 | 150 | 225 | 50 |
| ប្រាក់ចំនេញដុល (ដុល្លារ) | **430** | **571** | **33** | **277** | **383** | **38** |
| ពោត | | | | | | |
| ទិន្នផល (តោន) | | | | 4.0 | 4.0 | 0 |
| ថ្លៃទិញផ្ទាល់ពីកសិករ (ដុល្លារ/តោន) | | | | 150 | 250 | 67 |
| ប្រាក់ចំនូលដុល (ដុល្លារ) | | | | 600 | 1,000 | 67 |
| ចំនាយផលិតកម្មសរុប (ដុល្លារ) | | | | 205 | 280 | 37 |
| ប្រាក់ចំនេញដុល (ដុល្លារ) | | | | **395** | **720** | **82** |
| សណ្តែកសៀង | | | | | | |
| ទិន្នផល (តោន) | | | | 1.5 | 1.5 | 0 |
| ថ្លៃទិញផ្ទាល់ពីកសិករ (ដុល្លារ/តោន) | | | | 400 | 580 | 45 |
| ប្រាក់ចំនូលដុល (ដុល្លារ) | | | | 600 | 870 | 45 |
| ថ្លៃចំនាយផលិតកម្មសរុប (ដុល្លារ) | | | | 260 | 375 | 44 |
| ប្រាក់ចំនេញដុល (ដុល្លារ) | | | | **340** | **495** | **46** |
| ដំឡូងឈើ | | | | | | |
| ទិន្នផល (តោន) | | | | 8.0 | 8.0 | 0 |
| ថ្លៃទិញផ្ទាល់ពីកសិករ (ដុល្លារ/តោន) | | | | 75 | 160 | 113 |
| ប្រាក់ចំនូលដុល (ដុល្លារ) | | | | 600 | 1,280 | 113 |
| ថ្លៃចំនាយផលិតកម្មសរុប (ដុល្លារ) | | | | 288 | 420 | 46 |
| ប្រាក់ចំនេញដុល (ដុល្លារ) | | | | **312** | **860** | **176** |

* តួលេខនៅឆ្នាំ២០០៨ នេះ ទស្សន៍ទាយតាមថ្លៃ និងទិន្នផលបច្ចុប្បន្ន ។

ប្រភព : អង្កេតគ្រួសារសំរាប់ដំណាំស្រូវ និង ការពិភាក្សាក្រុមគោលដៅសំរាប់ដំណាំផ្សេងទៀត

### តារាង ៥: កំហិតលើកំណើនផលិតកម្ម បែងចែកតាមមុខដំណាំ (គ្រួសារគិតជា %)

| | ស្រូវវស្សា | ស្រូវប្រាំង | ពោត | ដំឡូងឈើ | ដំណាំផ្សេងៗ | សរុប |
|---|---|---|---|---|---|---|
| គ្មានប្រាក់គ្រប់គ្រាន់សំរាប់ទិញជី | 25.1 | 26.4 | 18.4 | 13.7 | 18.4 | 24.2 |
| គ្មានលទ្ធភាពស្រោចស្រព | 15.6 | 7.6 | 19.5 | 2.2 | 11.2 | 14.1 |
| គ្មានពលករ/គ្មានសត្វអូសទាញគ្រប់គ្រាន់ | 10.4 | 6.5 | 10.3 | 15.8 | 13.4 | 10.2 |
| គ្មានប្រាក់គ្រប់គ្រាន់ទិញថ្នាំសំលាប់សត្វល្អិត | 9.2 | 16.7 | 4.6 | 5.8 | 7.8 | 9.8 |
| ទឹកជំនន់/រាំងស្ងួត | 9.3 | 3.1 | 5.7 | 1.4 | 5.3 | 7.9 |
| គ្មានគ្រឿងចក្រគ្រប់គ្រាន់ | 5.9 | 6.8 | 1.1 | 21.6 | 6.9 | 6.5 |
| គ្មានប្រាក់គ្រប់គ្រាន់សំរាប់ជួលពលករ | 5.7 | 6.3 | 9.2 | 18.7 | 5.3 | 6.3 |
| គ្មានប្រាក់គ្រប់គ្រាន់សំរាប់ទិញពូជ | 3.8 | 7.4 | 8.0 | 2.9 | 4.4 | 4.4 |
| គ្មានចំណេះដឹង/គ្មានការបណ្តុះបណ្តាល | 4.0 | 1.7 | 8.0 | 5.8 | 10.3 | 4.2 |
| គ្មានប្រាក់គ្រប់គ្រាន់សំរាប់ធ្វើការស្រោចស្រព | 2.7 | 8.0 | 5.7 | 1.4 | 2.5 | 3.3 |
| គ្មានពេល រឺមានការងារផ្សេងធ្វើ | 0.5 | 0.2 | 2.3 | 2.2 | 1.6 | 0.6 |
| មិនអាចរកបានកំចី | 0.4 | 0.3 | 1.1 | 2.2 | 1.2 | 0.5 |
| អត្រាការប្រាក់ខ្ពស់ | 1.2 | 0.9 | 1.1 | 1.4 | 1.9 | 1.2 |
| កង្វះមធ្យោបាយដឹកជញ្ជូន | 2.4 | 2.3 | 2.3 | 2.9 | 3.1 | 2.5 |
| កង្វះច្រកចូលទីផ្សារ | 0.4 | 0.2 | 1.1 | 0.0 | 1.9 | 0.5 |
| ទំនាស់ដីធ្លី/ការព្រួយបារម្ភពីទំនាស់ដីធ្លី | 0.1 | 0.0 | 0.0 | 0.0 | 0.3 | 0.1 |
| ផ្សេងៗ | 3.4 | 5.6 | 1.1 | 2.2 | 4.7 | 3.8 |
| សរុប | 100.0 | 100.0 | 100.0 | 100.0 | 100.0 | 100.0 |

*ប្រភព: អង្កេតថ្នាក់ជាតិលើ ២២៣៥ គ្រួសារ នៅខែមិថុនា ២០០៨ ធ្វើឡើងដោយ CDRI*

នឹងបានចំនេញច្រើនជាងនៅឆ្នាំ២០០៧ ។ កសិករធ្វើស្រែប្រាំងទទួលបានអត្រាប្រាក់ចំនេញសុទ្ធរហូតដល់ ៣២% ថ្វីបើបន្ទុកចំនាយផលិតកម្មបានកើនឡើង ៥០% ក្តី ។ តារាង ៤ បង្ហាញយ៉ាងសង្ខេបពី ប្រាក់ចំនេញនៃផលដំណាំសំខាន់ៗនៅឆ្នាំ២០០៨ ។ ប្រសិនបើថ្លៃស្រូវវស្សានៅថេរត្រឹមកំរិតបច្ចុប្បន្ន ប្រាក់ចំនេញសុទ្ធរបស់ផលិតករ នឹងកើនឡើង ៤០% ។ ទន្ទឹមគ្នានេះ កសិករធ្វើស្រែវស្សា ត្រូវទទួលរ៉ាប់រងកំនើនថ្លៃផលិតកម្ម ៥០% និងការធ្លាក់ភ្លៀងមិនទៀងទាត់ ។ ជាជាងការកាត់បន្ថយធាតុចូល ដូចជា ជី ដែលបានឡើងថ្លៃមួយជាពីរ រឺមួយជាបីនោះ កសិករតែងខិតខំស្វែងរកកំចី រឺក៏ទិញជឿយ៉ាងថ្លៃនូវធាតុចូលកសិកម្ម ។

ស្រូវលក់បានថ្លៃខ្ពស់ បានជួយជំរុញផលិតកម្ម ។ មានកំណើនយ៉ាងហោចណាស់ក៏ ៣% ដែរ នូវចំនួនគ្រួសារដែលរាយការណ៍ថា នឹងដាំស្រូវលើដីធ្លីរបស់ខ្លួនក្នុងរដូវដាំដុះខាងមុខ ជាជាងទុកដីទំនេរចោល រឺក៏ជួលឱ្យអ្នកដទៃ ដូចកាលពីឆ្នាំមុន ។ ប៉ុន្តែមានកំហិតជាច្រើននិងជាយូរមកហើយដែរ លើការពង្រីក និងធ្វើប្រពលវប្បកម្មកសិកម្ម ។ កសិករជាច្រើនបានរាយការណ៍ថា ការឡើងថ្លៃជីយ៉ាងខ្លាំងនេះជាកំហិតមួយធំណាស់ ។ កំហិតផ្សេងទៀតមានដូចជា កង្វះកំលាំងពលកម្មក្នុងគ្រួសារ/សត្វអូសទាញ និងការគ្មានប្រព័ន្ធធារាសាស្ត្រ ។ តារាង ៥ បង្ហាញពីកំហិតសំរាប់មុខដំណាំសំខាន់ៗដែលបានសិក្សា ។

គួរមានមធ្យោបាយដើម្បីកាត់បន្ថយថ្លៃជីដែលបានកើនឡើងមួយជាពីរ រឺមួយជាបី ក្នុងឆ្នាំកន្លងទៅ ។ គេរាយកាណ៍ថា ជីគីមីទាំងអស់ត្រូវនាំចូលតាមច្រកព្រំដែនគ្មានប្រសិទ្ធិភាព ដោយពឹងផ្អែកយ៉ាងខ្លាំង និងជាលក្ខណៈក្រៅផ្លូវការ លើឈ្មួញវៀតណាម និងថៃ។ ការនាំចូលដុំ និងដោយផ្ទាល់នូវជី អាចជួយកាត់បន្ថយបន្ទុកចំណាយបានយ៉ាងច្រើន។រដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍គួរពិចារណាដោះស្រាយកំហិតដ៏ធំនេះ ដែលកសិករបានលើកឡើង និងយកចិត្តទុកដាក់លើការប្រើប្រាស់ជីគីមីឲ្យបានសមស្រប ។

កង្វះទឹក/ប្រព័ន្ធធារាសាស្ត្រជាបញ្ហាចំបង ថ្វីបើមានកំណើនគួរកត់សំគាល់នូវការផ្តល់ និងការតាំងចិត្តផ្តល់ប្រព័ន្ធធារាសាស្ត្ររបស់រដ្ឋាភិបាលក្តី ។ លទ្ធភាពគ្រប់គ្រងលើការផ្គត់ផ្គង់ទឹកមានសំរាប់តែ ៣០% នៃដីស្រែប៉ុណ្ណោះ ដែលបានផ្តល់ស្ថិរភាពនិងភាពប្រាកដប្រជាដល់ផលិតកម្មផលដំណាំ ។ កសិករក៏ត្រូវប្រើជាចាំបាច់ផងដែរនូវធាតុចូលផ្សេងទៀតដូចជា ជី និងពូជមានទិន្នផលខ្ពស់ ។ ការផ្គត់ផ្គង់ទឹក

## តារាង ៦: ស្ថានភាពកំចី

| | ភាគរយគ្រួសារជំពាក់បំណុលគេ | ភាគរយគ្រួសារបានខ្ចីបំណុលថ្មីក្នុងរយៈពេល ៦ខែកន្លងទៅ |
|---|---|---|
| ភ្នំពេញ | 33 | 20 |
| តំបន់វាលទំនាប | 52 | 23 |
| តំបន់ទន្លេសាប | 63 | 49 |
| តំបន់ខ្ពស់រាប | 44 | 34 |
| តំបន់ឆ្នេរ | 50 | 29 |
| សរុប | 53 | 32 |

ប្រភព: អង្កេតថ្នាក់ជាតិលើ ២២៣៥ គ្រួសារ នៅខែមិថុនា ២០០៨ ធ្វើឡើងដោយ CDRI

ដែលអាចទុកចិត្តបាន ជួយសំរួលការធ្វើប្រពលវប្បកម្ម និងកាត់បន្ថយបន្ទុកចំណាយផលិតកម្ម ។ បើគ្មានប្រព័ន្ធធារាសាស្ត្រ និងប្រព័ន្ធរំដោះទឹកទេ ផលិតកម្មក្នុងតំបន់ជាច្រើនមិនអាចធ្វើកើតរីក៏ប្រថុយខាតធំពេកនៅពេលមានប្រើធាតុចូលល្អៗ ។

កសិករជាច្រើនពុំមានមូលធនសំរាប់ចាប់ផ្តើម រីពង្រីកផលិតកម្មទេ ។ អ្នកខ្លះអាចទទួលបានកំចីដែលភាគច្រើន មានអត្រាការប្រាក់ខ្ពស់ ដើម្បីបន្តការងារផលិតកម្ម ។ កំចីនេះ បូកនឹងការខ្ចីបុលបន្ថែមសំរាប់ការប្រើប្រាស់ បានធ្វើឱ្យគ្រួសារប្រហែល ៥០% ត្រូវជំពាក់បំណុលគេ ហើយនេះជាកត្តាគួរឱ្យព្រួយបារម្ភ (តារាង ៦) ។ កសិករត្រូវការខ្ចីប្រាក់កាន់តែច្រើន ដើម្បីដោះស្រាយកំណើនបន្ទុកចំណាយផលិតកម្ម ជាពិសេស ជី ថ្នាំសំលាប់សត្វល្អិត គ្រឿងចក្រ និងពលកម្ម ។ រដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ត្រូវតែផ្តល់ទុនឲ្យអ្នកផ្តល់ឥណទាន និងកំណត់មុខសញ្ញាទុននេះសំរាប់បំរើកសិកម្ម ។ វិធានការនេះត្រូវមានប្រព័ន្ធតាមដានដ៏សក្តិសិទ្ធិមួយ ដើម្បីធានាថា ទុននោះបានទៅដល់ដៃកសិករពិតៗ និងបំរើសកម្មភាពផលិតកម្មយ៉ាងត្រឹមត្រូវ ។

ជំនួយបច្ចេកទេសតាមរយៈសេវាផ្សព្វផ្សាយបច្ចេកទេស ក៏គួរតែពង្រីកផងដែរ ។កំនើនការចែកចាយថ្នាំបង្ការសំរាប់សត្វចិញ្ចឹម អាចរួមចំនែកបានច្រើនណាស់ដល់ កំណើនការផ្គត់ផ្គង់ម្ហូបអាហារ និងការចុះថ្លៃទំនិញ ។ ព័ត៌មានទីផ្សារកសិកម្មក្នុងស្រុក និងអន្តរជាតិ គួរតែផ្សព្វផ្សាយកាន់តែទូលំទូលាយដល់ឈ្មួញ និងកសិករ ដើម្បីឲ្យពួកគេអាចមានគំនិតច្បាស់លាស់ពីនិន្នាការទីផ្សារ ។ មានការផ្តល់មតិមួយថា គួរប្រើប្រាស់ និងជួយគាំទ្រក្រុមកសិករនានាដែលមានស្រាប់ក្នុងការងារផ្សព្វផ្សាយព័ត៌មាននេះ ។ ផ្អែកលើស្ថានភាពល្អឡើងបែបនេះ ផលិតករខាងកសិកម្មអាច ចាប់យកឱកាសល្អនៃការឡើងថ្លៃកសិផលបានដោយបង្កើនផលិតកម្មសំរាប់នាំចេញ ។

ប្រទេសកម្ពុជាត្រូវតែអាចដឹងបានថា មានស្រូវនាំចេញប៉ុន្មានដើម្បីនឹងអាចដឹងពីបរិមាណស្បៀងដែលមាននៅក្នុងប្រទេស ។ សព្វថ្ងៃការនាំចេញស្រូវភាគច្រើនធ្វើឡើងជាលក្ខណៈក្រៅផ្លូវការ និងគ្មានការកត់ត្រាទេ ។ ដូច្នេះ ត្រូវយកចិត្តទុកដាក់ជាពិសេសសំរាប់រដូវក្រោយពីព្រោះតំបន់មួយចំនួនបានជួបការរាំងស្ងួត ។

សំរាប់យុទ្ធសាស្ត្ររយៈពេលវែង គួរមានគោលនយោបាយកាន់តែប្រសើរសំរាប់បែងចែក និងគ្រប់គ្រងដីធ្លី ។ គោលដៅបច្ចុប្បន្ននៃការរក្សាទុកគំរបព្រៃឈើលើ ៦០% នៃផ្ទៃប្រទេស អាចគួរឱ្យចង់បានមែន ប៉ុន្តែមិនសូវប្រាកដនិយមទេ នៅពេលសំពាធប្រជាសាស្ត្រនិងសេដ្ឋកិច្ចចោទឡើងខ្លាំងដាំង ។ ដោយសារគោលដៅនេះ ដីកសិកម្មថ្មីៗមានលក្ខណៈច្បាប់មិនច្បាស់លាស់ទេ ហើយច្រើនតែងាយស្រួលឲ្យពួកអ្នកមានប្រាក់ អំណាច ខ្សែរយៈខ្លាំង ប្រមែប្រមូលយក ចំណែកឯគ្រួសារជនបទភាគច្រើននៅតែជាអ្នកគ្មានដី រីមានដីតិច ។

ដោយអ្នកក្រីក្រ និងក្រីក្រខ្លាំង ត្រូវប៉ះពាល់ធ្ងន់ធ្ងរដោយការឡើងថ្លៃទំនិញ រដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលត្រូវធ្វើអន្តរាគមន៍ជាបន្ទាន់ ។ ជំនួយម្ហូបអាហារ និង/រីស្បៀងពលកម្ម អាចជាដំណោះស្រាយល្អបំផុត សំរាប់បំពេញតំរូវការរយៈពេលខ្លីរបស់ពួកគេ ។ ក្នុងអន្តរាគមន៍នេះត្រូវមានសហប្រតិបត្តិការកាន់តែខ្លាំងក្នុងចំណោមស្ថាប័នរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងសង្គមស៊ីវិល ។ ជំនួយឧបត្ថម្ភប្រភេទនេះ ប្រជាជនក្រីក្រដូចជាសហគមន៍នេសាទក្រីក្រជាដើម គាំទ្រខ្លាំងណាស់ ហើយក៏ធ្លាប់អនុវត្តហើយដែរនៅពេលមានគ្រោះរាំងស្ងួត និងទឹកជំនន់ ។ អន្តរាគមន៍ក៏ត្រូវមានយន្តការដ៏សក្តិសិទ្ធិផងដែរសំរាប់ផ្តល់ជំនួយឧបត្ថម្ភដោយផ្ទាល់ទៅអោយប្រជាជនក្រីក្រ ។

CDRI - វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
☞ ផ្ទះលេខ៥៦ ផ្លូវ៣១៥ ទួលគោក ភ្នំពេញ កម្ពុជា
✉ ប្រអប់សំបុត្រលេខ៦២២ ភ្នំពេញ កម្ពុជា
☎ (៨៥៥-២៣) ៨៨១-៣៨៤, ៨៨១-៧០១, ៨៨១-៩១៦, ៨៨៣-៦០៣, ០១២ ៨៦៧ ២៧៨
🖷 (៨៥៥-២៣) ៨៨០-៧៣៤
e-mail: cdrimail@online.com.kh
website: http://www.cdri.org.kh